**ជំនួយបច្ចេកទេសក្នុងការកសាងសមត្ថភាពថ្នាក់តំបន់**
**ការពង្រឹងសមត្ថភាពផ្នែកនីតិបរិស្ថាននៅអាស៊ី ប៉ាស៊ីហ្វិក៖**
**ការកសាងជើងឯកផ្នែកបរិស្ថាន**
**ការបណ្តុះបណ្តាលគ្រូបង្គោល**
**ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៧**
**ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា**

**គ្រឹះស្ថានអប់រំនីតិបរិស្ថាន IUCN**
**ការបណ្តុះបណ្តាលគ្រូបង្គោល**

## សេចក្តីសង្ខេបនៃការពន្យល់អំពីវិធីសាស្ត្របង្រៀន

(ចំពោះការពន្យល់ទាំងស្រុង សូមមើល IUCNAEL "ការពន្យល់អំពីវិធីសាស្ត្របង្រៀន" ក្នុងឯកសារមេរៀន)

| **ទម្រង់ និង វិធីសាស្ត្របង្រៀន** | **ទត្តបង្រៀន (ដែលត្រូវធ្វើការបង្ហាត់បង្ហាញ ឬ ពិភាក្សា)** | **សេចក្តីអធិប្បាយខ្លីៗ** |
|---|---|---|
| | **បែបផែននៃការបង្រៀន** | |
| ក. បឋកថា (ការបង្រៀនសិស្សច្រើន) | **14** | ជាបែបផែននៃការបង្រៀនពីមុន ជាពិសេសសម្រាប់ថ្នាក់មានសិស្សច្រើន ។ ផ្តល់បទពិសោធន៍សិក្សាអកម្មសម្រាប់សិស្ស ។ |
| ខ. ការបង្រៀនជាក្រុមតូច | **5** | ការពិភាក្សាក្រុមតូចៗ (5-10) អំពីលំហាត់ដែលបានរៀបចំជាមុនជាមួយគ្រូបង្រៀន ជារឿយៗចោទជាសំណួរដល់សិស្ស |
| គ. សិក្ខាសាលា | **14** | មានបញ្ចូលទាំងបែបផែនជាបឋកថា / ការបង្រៀនសិស្សចំនួន 20-30 នាក់ និងក៏មានបទបង្ហាញមួយចំនួនធ្វើឡើងដោយសិស្ស |

| | | |
|---|---|---|
| ឃ. ក្រុមតូច | **វិធីសាស្ត្រចម្រុះ** (សូមមើលវិធីសាស្ត្រ 11 & 13) | ជាធម្មតាសម្រាប់សិស្សពី 5 ទៅ 10 នាក់ ។ លើកទឹកចិត្តដល់សិស្សឱ្យចេះបញ្ចេញមតិ និងបង្កើនទំនុកចិត្តក្នុងការនិយាយ |
| ង. ការបង្រៀនតាមរយៈពិភាក្សាតាមប្រព័ន្ធអ៊ីនធឺណែត និងធ្វើសកម្មភាពក្នុងថ្នាក់ (Flipped classroom) | **14** | តម្រូវឱ្យមានបច្ចេកវិទ្យាកម្រិតខ្ពស់ដើម្បីអាចដោះស្រាយប្រធានបទដែលបានកំណត់ជាមុនរួមគ្នា និងស៊ីជម្រៅនៅក្នុងថ្នាក់ |
| **វិធីសាស្ត្របង្រៀន** | | |
| **ក. ការរៀនបែបឆ្លុះបញ្ចាំង** | | |
| 1. សំណេរឆ្លុះបញ្ចាំងពីបទពិសោធន៍រៀនរបស់សិស្ស (**Reflective journal**) | **1** | ស្រដៀងគ្នាទៅនឹងកំណត់ហេតុប្រចាំថ្ងៃ។ ដើម្បីកត់ត្រាលទ្ធផលសិក្សា បញ្ហាដែលត្រូវការការបញ្ជាក់បន្ថែម។ ល។ |
| 2. ការធ្វើដំណើរចុះទីវាល | **15 & 16** | ដើម្បីពង្រីកការយល់ដឹង និងបទពិសោធរបស់សិស្សចំពោះទិដ្ឋភាពផ្នែកច្បាប់នៃបញ្ហាបរិស្ថានជាក់ស្តែង |
| 3. ផ្តល់មតិត្រឡប់ជាលាយលក្ខណ៍អក្សរលើកិច្ចការដាក់ឱ្យសិស្សធ្វើ | **17** | អាចផ្តល់ពេលបញ្ចប់វគ្គ (ការផ្តល់លទ្ធផលវគ្គសិក្សា) ឬ អាចផ្តល់ពេលបញ្ចប់មេរៀននីមួយៗ (បង្ហាញថាតើចំនុចណាសិស្សធ្វើបានល្អ និងចំនុចណាដែលត្រូវកែលម្អ) |
| 4. ផ្តល់មតិត្រឡប់ផ្ទាល់មាត់ ក្នុងន័យស្ថាបនា | **8** | ជាការបង្រៀន សិក្ខាសាលា និងក្រុមតូចៗដើម្បីជំរុញការអភិវឌ្ឍគំនិត និងការយល់ដឹងអំពីទស្សនទានរួម |
| **ខ. គ្រូមជ្ឈមណ្ឌល** | | |

| | | |
|---|---|---|
| **5. គ្រូជាវាគ្មិន** | **9** | ផ្តល់ជំនាញបន្ថែមពីលើជំនាញរបស់គ្រូ (រួមទាំងជំនាញផ្សេងទៀតក្រៅពីច្បាប់) |
| 6. ករណីសិក្សា | **4 & 13** | ផ្តល់នូវវិធីសាស្ត្រជាក់ស្តែង និងស្របតាមបរិបទដើម្បីស្វែងយល់ពីចំនុចជាក់លាក់នានានៃនីតិបរិស្ថានអនុវត្តយ៉ាងដូចម្តេច |
| 7. ការសិក្សាពីច្បាប់ប្រៀបធៀប | **9** | ដើម្បីលើកកម្ពស់ការយល់ដឹងអំពីមធ្យោបាយផ្សេងៗដែលនីតិបរិស្ថានអនុវត្តចំពោះបញ្ហាស្រដៀងគ្នាក្នុងយុត្តាធិការផ្សេងគ្នា |
| 8. ភាពយន្ត/វីដេអូ | **2A & 6** | បំពេញបន្ថែមលើការពិភាក្សាក្នុងថ្នាក់ទាក់ទងទៅនឹងបញ្ហាបរិស្ថានជាក់ស្តែង |
| **9. ប្រភពឯកសារអេឡិចត្រូនិក** | **14** | ពង្រឹងការធ្វើបថកថា និងសិក្ខាសាលាដោយបង្ហាញពីប្រភពឯកសារតាមអ៊ិនធឺណិត (ច្បាប់។ល។) ក្នុងពេលរៀន |
| **គ. សិស្សមជ្ឈមណ្ឌល** | | |
| 10. ធ្វើលំហាត់ជាក្រុមតូច | **3** | ដើម្បីបង្កើនការយល់ដឹងរបស់សិស្សអំពីគំនិតជាមូលដ្ឋាននៃនីតិបរិស្ថាន (ឧ. និយមន័យនៃ "បរិស្ថាន") |
| **11. ការពិភាក្សាតាមការណែនាំ (ក្រុមតូច និងធ្វើការរាយការណ៍)** | **2B, 3 – 7, 10** | អនុញ្ញាតឱ្យសិស្សធ្វើការពិភាក្សាអំពីចំនុច ឬបញ្ហាជាក់ស្តែង ហើយរាយការណ៍ពីការពិភាក្សារបស់ខ្លួន |
| **12. ការពិភាក្សាតាមការណែនាំ (សិស្សក្នុងថ្នាក់ទាំងមូល)** | **13 &16** | ក្នុងការបង្រៀន ឬសិក្ខាសាលាអាច ពិភាក្សាលើចំណុច ឬបញ្ហាជាក់ស្តែង (ព្រមទាំងមានការជួយសម្រួលតាមរយៈការបង្រៀន) |
| **13. ការពិភាក្សាដោយសេរី (លក្ខណៈពិភាក្សាដោយសេរី)** | **3,6 & 17** | ការគ្រប់គ្រងរបស់គ្រូមានតិចតួច។ អនុញ្ញាតឱ្យសិស្សកំណត់វិន័យផ្ទាល់ខ្លួនក្នុងការប្រាស្រ័យ |

| | | |
|---|---|---|
| | | ទាក់ទងជាមួយក្រុមតូចមួយនៃថ្នាក់ពេញម៉ោង |
| **14. ការពិភាក្សាផ្តល់គំនិតយោបល់** | **8** | ស្រដៀងគ្នាទៅនឹងការពិភាក្សាដោយសេរីប៉ុន្តែផ្តោតលើការបង្កើតគំនិតជាក់លាក់នៅលើប្រធានបទជាក់លាក់មួយ (ជាញឹកញាប់មានការប្រៀបធៀបដើម្បីពិនិត្យឡើងវិញនៅក្នុងថ្នាក់ទាំងមូល) |
| **ឃ. ជំនាញស្រាវជ្រាវ** | | |
| **15. លំហាត់ស្រាវជ្រាវដែលបានណែនាំ** | **8 & 11** | ដើម្បីលើកកម្ពស់ទាំងការងារស្រាវជ្រាវផ្នែកច្បាប់ និងជំនាញធ្វើបទបង្ហាញសម្រាប់សិស្សម្នាក់ៗ ឬធ្វើការជាក្រុមតូច |
| **16. លំហាត់សម្តែងតួ** | **7 & 12** | ពិសេសសមស្របចំពោះដំណើរការសម្រុះសម្រួល ឬចរចារ។ អនុញ្ញាតឱ្យសិស្សអភិវឌ្ឍន៍ជំនាញធ្វើបទបង្ហាញនិ ងយល់ដឹងកាន់តែច្បាស់អំពីជាតុផ្សំនៃចំនុចវិវាទផ្នែកបរិស្ថាន |
| **17. វែកញែកពីបញ្ហាច្បាប់តាមរយៈសវនាការប្រឌិត** (Mooting) | **11** | ដើម្បីស្វែងយល់ពីបែបបទដែលពាក់ព័ន្ធនឹងការធ្វើសារណាទៅតុលាការ និងដើម្បីអភិវឌ្ឍន៍ជំនាញក្នុងការស្រាវជ្រាវច្បាប់ |
| **18. ការដោះស្រាយសំណុំរឿងជាក់ស្តែង** (Legal Clinics) | **10** | ដើម្បីអភិវឌ្ឍជំនាញអនុវត្តជាក់ស្តែង ដូចជាការរៀបចំសេចក្តីព្រាង ឬ ទស្លីករណ៍ជាលាយលក្ខណ៍អក្សរ ឬការដាក់គោលនយោបាយ ការសម្ភាសន៍ និងធ្វើជាតំណាងឱ្យកូនក្តី។ ដើម្បីផ្តល់ជូននូវបទពិសោធន៍ជាក់ស្តែងលើសំណុំរឿងពិតប្រាកដ។ |